# ហ្វីលីពរកឃើញផ្លូវ

ដោយ មេហ្គិន រ៉ូហ្វាស
( ផ្អែកទៅលើដំណើររឿងពិត )

ហ្វីលីពដឹងថាវាជិតយប់ហើយ ។ សត្វបក្សាបក្សីបានឈប់ស្រែកយំ ហើយសត្វចង្រិតក៏បន្លឺសំឡេងយ៉ាងខ្លាំង ។ គាត់ និងម្ដាយរបស់គាត់បានដើរនៅក្នុងព្រៃអស់ជាងពីរម៉ោង ។ ប៉ុន្តែផ្លូវនីមួយៗដែលពួកគាត់បានដើរទៅគឺចុងក្រោយមើលទៅដូចគ្នា ។ ពួកគាត់បានវង្វេងផ្លូវ ។

ហ្វីលីពបានចាប់ផ្ដើមខ្លាចយ៉ាងខ្លាំង ។ តើពួកគាត់អាចរស់នៅក្នុងព្រៃនេះបានយូរប៉ុណ្ណា ? គាត់ទើបតែអាយុ ១០ ឆ្នាំប៉ុណ្ណោះ ។ វ័យនេះពុំធំគ្រប់គ្រាន់ដើម្បីវាយតបនឹងសត្វពស់ ឬជ្រូកព្រៃនោះទេ ។ ហើយតើសត្វដ៏គួរឲ្យខ្លាចផ្សេងៗទៀតណាខ្លះដែលអាចដើរក្រវែលក្រោយថ្ងៃលិច ? គំនិតនេះបានធ្វើឲ្យគាត់ខ្លាចព្រឺឆ្អឹងខ្នង ។

*ត្រូវក្លាហាន* គាត់បានប្រាប់ខ្លួនឯង ។ គាត់បានដឹងថាគាត់ត្រូវតែក្លាហាន ។

ហ្វីលីពចង់ឲ្យប៉ាគាត់នៅទីនោះ ។ ប៉ុន្តែគាត់បានស្លាប់ប្រាំមួយខែកន្លងទៅហើយ ។ ដោយគ្មានគាត់ អ្វីៗជាច្រើនមានការលំបាកសម្រាប់ហ្វីលីព និងម៉ាក់របស់គាត់ ។ ពួកគាត់បានអស់លុយ និងអាហារ ។

ហ្វីលីពបានសង្ឃឹមថាពួកគាត់នឹងអាចទៅដល់ផ្ទះបងស្រីរបស់គាត់នៅជើងភ្នំម្ខាងទៀតឆាប់ៗ ។ នាងអាចឲ្យលុយខ្លះដល់ពួកគាត់ទិញអង្ករ ។

គាត់បានពោលពាក្យអធិស្ឋាននៅក្នុងចិត្តរបស់គាត់ ។ « ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមជួយពួកកូនអាចរកផ្លូវឃើញផង ។ *ឱ ព្រះវរបិតាអើយ* » ។

បន្ទាប់មក គំនិតមួយបានផុសឡើងចំពោះគាត់ ៖ *មើលទៅដើមដូងនោះទៅ* ។ ហ្វីលីពបានមើលទៅលើ ។ នៅទីនោះពីចម្ងាយមានចម្ការដើមដូង ។ គាត់អាចឃើញដើមដូងទាំងនោះខ្ពស់ជាងព្រៃផ្សេងៗ ។ ស្លឹកដូងបក់គ្រវីក្នុងអាកាស ។ អស់ជាច្រើនម៉ោង នេះជាលើកទីមួយហើយដែលហ្វីលីពបានមានអារម្មណ៍ថាមានសង្ឃឹម ។

« មើលហ្ន៎ ! » គាត់បានចង្អុលទៅដើមនោះ ។

ម្ដាយរបស់គាត់បានយល់ ។ ដើមដូងមានន័យថា មានតូមិនៅក្បែរ ។ ព្រះបានឆ្លើយតបការអធិស្ឋានរបស់ហ្វីលីព ។ ហ្វីលីពបានកាន់ដៃម្ដាយរបស់គាត់ ។ ពួកគាត់បានដើរទៅរកទីសុវត្ថិភាពកាលដែលព្រះអាទិត្យលិចទាបជាងដើមឈើ ។



ប្រទេសហ្វីលីពីនមានកោះជាង ៧,៦០០ កោះ !



ប្រទេសនេះជាជម្រករបស់រុក្ខជាតិ និងសត្វគ្រប់ប្រភេទចំនួន ៧០% នៃពិភពលោក ។



មិនយូរប៉ុន្មានប្រទេសហ្វីលីពីននឹងមានព្រះវិហារបរិសុទ្ធចំនួនប្រាំបី ។



ហ្វីលីព និងភរិយារបស់គាត់បានសន្សំលុយអស់រយៈពេលមួយឆ្នាំ ដើម្បីពួកគាត់អាចធ្វើដំណើរទៅផ្សារភ្ជាប់នៅព្រះវិហារបរិសុទ្ធ ។



ហ្វីលីពចូលចិត្តស្ទូចត្រី ។



ហ្វីលីព និងភរិយារបស់លោក ខូវ៉ា មានកូនបួននាក់ និងចៅ ១០ នាក់ ។



**ហ្វីលីព បានអធិស្ឋានថា « សូមជួយពួកកូនរកឃើញផ្លូវ » ។**

ហ្វីលីពតែងតែចងចាំជានិច្ចពីរបៀបដែលព្រះបានឆ្លើយតបការអធិស្ឋានរបស់គាត់ ។ នៅពេលខ្លះ គាត់ប្រាថ្នាថាគាត់ អាចស្ដាប់ឮព្រះសូរសៀងរបស់ព្រះបានប្រសើរជាង ដូចជាអ្វីដែលគាត់បានឮនាយប់នៅក្នុងព្រៃនោះ ។

បន្ទាប់មកនៅថ្ងៃមួយ នៅប្រាំបីឆ្នាំក្រោយមក ហ្វីលីពបានជួបនឹងពួកអ្នកផ្សព្វផ្សាយសាសនាមួយចំនួន ។ ពួកគេបានមកពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ពួកគេបានបង្រៀនគាត់ពីពួកព្យាការីដែលនៅរស់ ដែលពួកលោកមានប្រសាសន៍ពីព្រះបន្ទូលរបស់ព្រះ ។ នេះគឺជាអ្វីដែលហ្វីលីពប្រាថ្នាចង់បាន !

ហ្វីលីពបានមានចិត្តរំភើបដើម្បីចូលរួមនៅក្នុងសាសនាចក្រនេះ ។ គាត់បានធ្វើជាអ្នកផ្សព្វផ្សាយសាសនាដំបូងម្នាក់មកពីប្រទេសហ្វីលីពីន ដើម្បីចែកចាយដំណឹងល្អនៅទីនោះ ។ ជាថ្មីម្ដងទៀត ព្រះបានបង្ហាញហ្វីលីពកន្លែងដើម្បីទៅ—ហើយហ្វីលីពតែងតែដឹងថាព្រះឆ្លើយតបជានិច្ច ។●

